ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ១១៣៥ MISTI / ២០២០

ថ្ងៃ ចន្ទ ១០រោច ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០២០

# សេចក្ដីណែនាំ
# ស្ដីពី
# ការអនុវត្តការងារមាត្រាសាស្ត្រ
# ផ្នែកឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេង

កន្លងមក រាជរដ្ឋាភិបាលបានដាក់ចេញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្ដីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណងប្រមូលផ្ដុំការផ្ដល់សេវាលើវិស័យនានានៅកន្លែងតែមួយ ដើម្បីបង្កលក្ខណៈងាយស្រួល និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ដែលក្នុងនោះក៏មានការធ្វើប្រតិភូកម្មឱ្យរដ្ឋបាលរាជធានី ខេត្ត ក្នុងការផ្ដល់សេវាត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេង តាមបណ្ដាស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈផងដែរ។

ដើម្បីធានាដល់ប្រសិទ្ធភាពនៃការអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មខាងលើនេះ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សូមធ្វើការណែនាំដូចខាងក្រោម៖

## I- ការស្នើសុំសេវាត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ (ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេង

ម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈទាំងអស់ មានកាតព្វកិច្ចដាក់ពាក្យស្នើសុំត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេងទាំងអស់នៅក្នុងស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈរបស់ខ្លួនមុនពេលប្រើប្រាស់ និងក្នុងអំឡុងពេលប្រើប្រាស់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេង សម្រាប់ធ្វើអាជីវកម្មតាមការកំណត់របស់រដ្ឋបាលរាជធានី ខេត្ត។

ការផ្ដល់សេវាត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេង មានសេវា ០២ប្រភេទ ដូចខាងក្រោម៖

១. សេវាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង៖ សំដៅដល់សេវាលើការត្រួតពិនិត្យផ្ទៀងផ្ទាត់លើឧបករណ៍មាត្រាសាស្ត្រថ្មី ឬដែលបានជួសជុលរួច មុនពេលដាក់ឱ្យប្រើប្រាស់

២. សេវាត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់៖ សំដៅដល់សេវាលើបណ្ដាប្រភេទនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍ទម្ងន់ និងរង្វាស់រង្វាល់ដែលបានត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូងរួចហើយ និងកំពុងប្រើប្រាស់។

### ១. ការស្នើសុំសេវាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង

ម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈទាំងអស់ មានកាតព្វកិច្ចដាក់ពាក្យស្នើសុំត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេងទាំងអស់នៅក្នុងស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈរបស់ខ្លួន មុនពេលប្រើប្រាស់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេង



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: misti.smcabinet@gmail.com

សម្រាប់ធ្វើអាជីវកម្មរបស់ខ្លួន។ ក្នុងករណីម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈខកខានមិនបានដាក់ពាក្យស្នើសុំត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេងទាំងអស់នៅក្នុងស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈរបស់ខ្លួន ម្ចាស់នោះត្រូវទទួលការពិន័យដូចបានកំណត់ក្នុងច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ក.ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់**

ម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈត្រូវមកទទួលពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នៅអង្គភាពច្រកចេញចូលតែមួយរបស់រដ្ឋបាលរាជធានី ខេត្ត ដោយត្រូវបំពេញសំណុំឯកសារភ្ជាប់ដូចខាងក្រោម៖

- ពាក្យស្នើសុំ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លង(សម្រាប់ប្រជាពលរដ្ឋខ្មែរ) ឬលិខិតឆ្លងដែនថតចម្លង(សម្រាប់ជនបរទេស) ដែលមានការបញ្ជាក់ពីអាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ច ឬមានការផ្ទិតមេដៃទទួលស្គាល់ដោយសាមីខ្លួន

**ខ. នីតិវិធីនៃការផ្តល់សេវា**

បន្ទាប់ពីពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់ត្រូវបានបំពេញត្រឹមត្រូវ និងគ្រប់គ្រាន់ ម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈត្រូវមកដាក់ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដែលស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈនោះតាំងនៅ។ ដំណើរការនៃការផ្តល់សេវាត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ក្រោយពីទទួលបានពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នានាពីប្រធានអង្គភាពច្រកចេញចូលតែមួយបុគ្គលិកផ្នែកជួរក្រោយត្រូវពិគ្រោះយោបល់ជាមួយប្រធានអង្គភាពច្រកចេញចូលតែមួយ ធ្វើការកំណត់កាលបរិច្ឆេទជាក់លាក់ ដើម្បីចុះត្រួតពិនិត្យផ្ទៀងផ្ទាត់តាមបណ្តាស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈដែលបានដាក់ពាក្យស្នើសុំរួច ចំពោះកាលបរិច្ឆេទនៃការចុះត្រួតពិនិត្យផ្ទៀងផ្ទាត់បច្ចេកទេសខាងលើត្រូវធ្វើឡើងក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់តាំងពីថ្ងៃទទួលឯកសារពីប្រធានអង្គភាពច្រកចេញចូលតែមួយ
- បន្ទាប់ពីបានចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេងនៅតាមស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈ ក្នុងករណីរកឃើញថា ៖

១. ឧបករណ៍នោះត្រឹមត្រូវ មន្ត្រីត្រួតពិនិត្យបច្ចេកទេសត្រូវ៖

+ កិបសៀល និងដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់(បិទស្ទីកគ័រ) បញ្ជាក់ពីភាពត្រឹមត្រូវលើឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេងនោះ
+ រៀបចំកំណត់ហេតុបច្ចេកទេសនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងកំណត់បង្ហាញរឿង ដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំនោះ។ បុគ្គលិកជួរក្រោយដែលស្ថិតនៅក្នុងអង្គភាពច្រកចេញចូលតែមួយត្រូវផលិតសេចក្តីព្រាងលិខិតអនុញ្ញាត ដើម្បីដាក់ជូនប្រធានអង្គភាពច្រកចេញចូលតែមួយ។

<u>**បញ្ជាក់**</u>៖ ក្នុងករណីនេះ ម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈ អាចប្រើប្រាស់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេង ដែលត្រូវបានកិបសៀល និងដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់បញ្ជាក់ពីភាពត្រឹមត្រូវរួចរាល់សម្រាប់ដំណើរការអាជីវកម្មរបស់ខ្លួនបាន ក្នុងអំឡុងពេលរង់ចាំលិខិតអនុញ្ញាតផ្លូវការពីរដ្ឋបាលរាជធានី ខេត្ត។

២. ឧបករណ៍នោះមិនត្រឹមត្រូវ មន្ត្រីត្រួតពិនិត្យបច្ចេកទេសត្រូវ៖

+ បិទ ឬដាក់ស្លាកសញ្ញាផ្អាកការប្រើប្រាស់
+ រៀបចំកំណត់ហេតុបច្ចេកទេសនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងកំណត់បង្ហាញរឿង ដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំនោះ។ បុគ្គលិកជួរក្រោយដែលស្ថិតនៅក្នុងអង្គភាពច្រកចេញចូលតែមួយត្រូវផលិតសេចក្តីព្រាងលិខិតជូនដំណឹងកែតម្រូវ ដើម្បីដាក់ជូនប្រធានអង្គភាពច្រកចេញចូលតែមួយ។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: mistismcabinet@gmail.com

បញ្ជាក់៖ ក្នុងករណីនេះ ម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈ ត្រូវមកដាក់ពាក្យស្នើសុំត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូងឡើងវិញនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្រោយពីបានធ្វើការជួសជុលកែតម្រូវរួច។

- បន្ទាប់ពីទទួលបានការផ្តល់យោបល់ពីផ្នែកជួរក្រោយ ប្រធានអង្គភាពច្រកចេញចូលតែមួយត្រូវរៀបចំសំណុំឯកសារស្នើសុំសេវានោះ និងសេចក្តីព្រាងលិខិតអនុញ្ញាត ឬលិខិតជួសជុលកែតម្រូវ ដាក់ជូនអភិបាលរាជធានី ខេត្ត ឬអ្នកដែលមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន។

## ២. ការស្នើសុំសេវាត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់

អំឡុងពេលដាក់ឱ្យប្រើប្រាស់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរ៉ៃបូមប្រេងនៅតាមស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈ មុនពេលអស់សុពលភាពរយៈពេល ១(មួយ)ខែនៃលិខិតអនុញ្ញាតប្រើប្រាស់ ម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈមានកាតព្វកិច្ចមកដាក់ពាក្យស្នើសុំសេវាត្រួតពិនិត្យផ្ទៀងផ្ទាត់ ក្នុងពេលប្រើប្រាស់ឡើងវិញនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត។

ក្នុងករណីដែលម្ចាស់ស្ថានីយ/អនុស្ថានីយ (ដេប៉ូ) ប្រេងឥន្ធនៈមិនបានដាក់ពាក្យស្នើសុំសេវាត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ឡើងវិញនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្តទេ រដ្ឋបាលរាជធានី ខេត្តដែលមានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាសេនាធិការ ត្រូវរៀបចំកម្មវិធីប្រចាំឆ្នាំដោយកំណត់ចំនួន និងទីតាំងស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈ ដើម្បីចុះទៅត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ (ប្រេង-ឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរ៉ៃបូមប្រេងក្នុងពេលប្រើប្រាស់នោះជារៀងរាល់ខែ។ ផ្អែកលើកម្មវិធីនេះ រដ្ឋបាលរាជធានី ខេត្តត្រូវចាត់តាំងក្រុមការងារដែលមានសមាសភាពតំណាងអង្គភាពច្រកចេញចូលតែមួយ បុគ្គលិកទទួលបន្ទុកបេឡា បុគ្គលិកជួរក្រោយដែលជាមន្ត្រីត្រួតពិនិត្យ និង/ឬតំណាងការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ដើម្បីរៀបចំបែបបទចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេសឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរ៉ៃបូមប្រេងក្នុងពេលប្រើប្រាស់នៅតាមស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈដែលបានកំណត់។

### ក.ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់

ម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈត្រូវមកទទួលពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នៅអង្គភាពច្រកចេញចូលតែមួយរបស់រដ្ឋបាលរាជធានី ខេត្ត ដោយត្រូវបំពេញសំណុំឯកសារភ្ជាប់ដូចខាងក្រោម៖

- លិខិតអនុញ្ញាតប្រើប្រាស់(លើកដំបូង ឬក្នុងពេលប្រើប្រាស់លើកមុន)
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លង(សម្រាប់ប្រជាពលរដ្ឋខ្មែរ) ឬលិខិតឆ្លងដែនថតចម្លង(សម្រាប់ជនបរទេស) ដែលមានការបញ្ជាក់ពីអាជ្ញាធរ ឬស្ថាប័នមានសមត្ថកិច្ច ឬមានការផ្តិតមេដៃទទួលស្គាល់ដោយសាមីខ្លួន។

ចំពោះការចុះត្រួតពិនិត្យផ្ទៀងផ្ទាត់តាមកម្មវិធី ក្រុមការងារត្រូវយកទៅជាមួយនូវពាក្យស្នើសុំ ដើម្បីឱ្យម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈបំពេញ និងបង្កាន់ដៃបង់ប្រាក់។

### ខ.នីតិវិធីនៃការផ្តល់សេវា

ចំពោះម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈ ដែលបានដាក់ពាក្យស្នើសុំត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ឡើងវិញនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដំណើរការនៃការផ្តល់សេវាត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ក្រោយពីទទួលបានពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នានាពីប្រធានអង្គភាពច្រកចេញចូលតែមួយបុគ្គលិកផ្នែកជួរក្រោយត្រូវពិគ្រោះយោបល់ជាមួយប្រធានអង្គភាពច្រកចេញចូលតែមួយ ធ្វើការកំណត់កាលបរិច្ឆេទជាក់លាក់ ដើម្បីចុះត្រួតពិនិត្យផ្ទៀងផ្ទាត់តាមបណ្តាស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈដែលបានដាក់



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

ពាក្យស្នើសុំរួច ចំពោះកាលបរិច្ឆេទនៃការចុះត្រួតពិនិត្យផ្ទៀងផ្ទាត់បច្ចេកទេសខាងលើត្រូវធ្វើឡើងក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់តាំងពីថ្ងៃទទួលឯកសារពីប្រធានអង្គភាពច្រកចេញចូលតែមួយ

- បន្ទាប់ពីបានចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេងនៅតាមស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈ ក្នុងករណីរកឃើញថា៖

១. ឧបករណ៍នោះត្រឹមត្រូវ មន្ត្រីត្រួតពិនិត្យបច្ចេកទេសត្រូវ៖

+ កិបសៀល និងដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់(បិទស្ទីកគ័រ) បញ្ជាក់ពីភាពត្រឹមត្រូវលើឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេងនោះ

+ រៀបចំកំណត់ហេតុបច្ចេកទេសនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងកំណត់បង្ហាញរឿង ដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំនោះ។ បុគ្គលិកជួរក្រោយដែលស្ថិតនៅក្នុងអង្គភាពច្រកចេញចូលតែមួយត្រូវផលិតសេចក្តីព្រាងលិខិតអនុញ្ញាត ដើម្បីដាក់ជូនប្រធានអង្គភាពច្រកចេញចូលតែមួយ។

**បញ្ជាក់៖** ក្នុងករណីនេះ ម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈ អាចប្រើប្រាស់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេង ដែលត្រូវបានកិបសៀល និងដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់បញ្ជាក់ពីភាពត្រឹមត្រូវរួចរាល់សម្រាប់ដំណើរការអាជីវកម្មរបស់ខ្លួនបាន ក្នុងអំឡុងពេលរង់ចាំលិខិតអនុញ្ញាតផ្លូវការពីរដ្ឋបាលរាជធានី ខេត្ត។

**បញ្ជាក់៖** ក្នុងករណីនេះ ម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈ អាចប្រើប្រាស់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេង ដែលត្រូវបានកិបសៀល និងដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់បញ្ជាក់ពីភាពត្រឹមត្រូវរួចរាល់សម្រាប់ដំណើរការអាជីវកម្មរបស់ខ្លួនបាន ដោយមិនចាំបាច់រង់ចាំលិខិតអនុញ្ញាតផ្លូវការពីរដ្ឋបាលរាជធានី ខេត្តឡើយ។

២. ឧបករណ៍នោះមិនត្រឹមត្រូវ មន្ត្រីត្រួតពិនិត្យបច្ចេកទេសត្រូវ៖

+ បិទ ឬដាក់ស្លាកសញ្ញាផ្អាកការប្រើប្រាស់

+ រៀបចំកំណត់ហេតុបច្ចេកទេសនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងកំណត់បង្ហាញរឿង ដោយផ្តល់យោបល់បច្ចេកទេសលើសេវាដែលបានស្នើសុំនោះ។ បុគ្គលិកជួរក្រោយដែលស្ថិតនៅក្នុងអង្គភាពច្រកចេញចូលតែមួយត្រូវផលិតសេចក្តីព្រាងលិខិតជួសជុលកែតម្រូវ ដើម្បីដាក់ជូនប្រធានអង្គភាពច្រកចេញចូលតែមួយ។

**បញ្ជាក់៖** ក្នុងករណីនេះ ម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈ ត្រូវមកដាក់ពាក្យស្នើសុំត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូងឡើងវិញនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្រោយពីបានធ្វើការជួសជុលកែតម្រូវរួច។

- បន្ទាប់ពីទទួលបានការផ្តល់យោបល់ពីផ្នែកជួរក្រោយ ប្រធានអង្គភាពច្រកចេញចូលតែមួយត្រូវរៀបចំសំណុំឯកសារស្នើសុំសេវានោះ និងសេចក្តីព្រាងលិខិតអនុញ្ញាត ឬលិខិតជួសជុលកែតម្រូវ ដាក់ជូនអភិបាលរាជធានី ខេត្ត ឬអ្នកដែលមានសិទ្ធិសម្រេច ដើម្បីចុះហត្ថលេខាតាមនីតិវិធីជាធរមាន។

សម្រាប់ការចុះត្រួតពិនិត្យផ្ទៀងផ្ទាត់តាមកម្មវិធី ចំពោះស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈដែលម្ចាស់មិនបានដាក់ពាក្យស្នើសុំត្រួតពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលប្រើប្រាស់ឡើងវិញ នីតិវិធីនៃការផ្តល់សេវាត្រូវអនុវត្តដូចខាងក្រោម៖

- តម្រូវឱ្យម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈ បំពេញពាក្យស្នើសុំ និងភ្ជាប់នូវសំណុំឯកសារដូចបានកំណត់ក្នុងចំណុច "ក" ព្រមទាំងបង់កម្រៃសេវា ស្របតាមលិខិតបទដ្ឋានគតិយុត្តដែលបានកំណត់

- បន្ទាប់មក ក្រុមការងារត្រូវអនុវត្តនីតិវិធីត្រួតពិនិត្យផ្ទៀងផ្ទាត់ដូចបានកំណត់ខាងលើ។



ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**II-កម្រៃសេវា និងសុពលភាព**

កម្រៃសេវា និងសុពលភាពនៃលិខិតអនុញ្ញាតត្រូវអនុវត្តតាមប្រកាសរួមរវាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬលិខិតបទដ្ឋានជាធរមាន។

**III-របាយការណ៍**

រដ្ឋបាលរាជធានី ខេត្តត្រូវធ្វើរបាយការណ៍ជាទៀងទាត់អំពីការចេញលិខិតអនុញ្ញាត និងលិខិតជួសជុលកែតម្រូវសម្រាប់ការផ្តល់សេវាខាងលើមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយចម្លងជូនក្រសួងមហាផ្ទៃតាមគោលការណ៍កំណត់។

ទទួលបានសេចក្តីណែនាំនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងរដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយដោយស្មារតីទទួលខុសត្រូវខ្ពស់។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា**
**និងនវានុវត្តន៍**

*កិត្តិសេដ្ឋាបណ្ឌិត* **ចម ប្រសិទ្ធ**

**ចម្លងជូន ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ


ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: misti.smcabinet@gmail.com

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Logo រដ្ឋបាល
រាជធានី/ខេត្ត

**រដ្ឋបាលរាជធានី/ខេត្ត.....................**
លេខ .............................

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ (ប្រេងឥន្ធនៈ)**
**ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេង សម្រាប់ឆ្នាំ...............**

**យោង** ៖ - ព្រះរាជក្រម នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- ប្រកាសលេខ ៤១១ MIH/2014 ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៤ ស្តីពីបទប្បញ្ញត្តិបច្ចេកទេសត្រួតពិនិត្យផ្ទៀងផ្ទាត់កុងទ័រចែកចាយប្រេងឥន្ធន។

រដ្ឋបាលរាជធានី/ខេត្ត...................មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈទាំងអស់ដែលកំពុងធ្វើសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្មនៅទូទាំងរាជធានី/ខេត្ត.....................ឲ្យបានជ្រាបថា៖ រដ្ឋបាលរាជធានី/ខេត្ត....................... ដែលមានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាអង្គភាពជំនាញ នឹងចាប់ផ្តើមអនុវត្តការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង និងក្នុងពេលប្រើប្រាស់សម្រាប់ឆ្នាំ........ តាមកម្មវិធីចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ដែលបានកំណត់ (ដូចភ្ជាប់ជូនជាមួយ) ទៅលើសុក្រឹតភាពផ្នែករង្វាស់រង្វាល់នៃឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ)ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេងនៅតាមបណ្តាស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈរបស់លោក លោកស្រី សំដៅជានាផលប្រយោជន៍រវាងលោក លោកស្រីដែលជាម្ចាស់ និងប្រជាពលរដ្ឋទូទៅដែលជាអ្នកទទួលទិញប្រេងឥន្ធនៈទាំងអស់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលរាជធានី/ខេត្ត......... ។

ចំពោះឧបករណ៍បែងចែកវត្ថុរាវ (ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេងទាំងឡាយណា ដែលមិនមានការត្រួតពិនិត្យផ្ទៀងផ្ទាត់ ដាក់ស្លាកសញ្ញាត្រួតពិនិត្យត្រឹមត្រូវ និងមានលិខិតអនុញ្ញាតប្រើប្រាស់ រដ្ឋបាលរាជធានី/ខេត្ត.................នឹងចាត់វិធានការចំពោះម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈនោះស្របតាមច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជាដូចមានចែងក្នុងជំពូកទី ១០ ស្តីពីទោសប្បញ្ញត្តិជាកំហិត ដោយសហការជាមួយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីព្រមាន ពិន័យអន្តរការណ៍ជាប្រាក់ និង/ឬ រៀបចំសំណុំរឿងបញ្ជូនទៅតុលាការមានសមត្ថកិច្ច។

អាស្រ័យហេតុនេះ សូមលោក លោកស្រីដែលជាម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈទាំងអស់ សហការអនុវត្តកិច្ចការត្រួតពិនិត្យផ្ទៀងផ្ទាត់តាមសេចក្តីជូនដំណឹងនេះឲ្យមានប្រសិទ្ធភាពខ្ពស់ និងស្របតាមច្បាប់ដែលបានកំណត់។ សូមលោក លោកស្រី អញ្ជើញមកទាក់ទងនៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី/ខេត្ត.............................. ដែលមានទីតាំងនៅក្នុងសាលារាជធានី/ខេត្ត.......................... ផ្លូវលេខ.......................... សង្កាត់....................... ក្រុង/ខណ្ឌ............................ រាជធានី/ខេត្ត............................ ឬ តាមរយៈទូរសព្ទលេខ៖........................................ និង អ៊ីម៉ែល៖............................................ ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ(នៅរៀងរាល់ម៉ោងធ្វើការ) ដើម្បីរៀបចំសំណុំឯកសារស្នើសុំត្រួតពិនិត្យផ្ទៀងផ្ទាត់របស់លោក លោកស្រី ហើយត្រូវបង្កលក្ខណៈងាយស្រួលដល់ការបំពេញភារកិច្ចរបស់មន្ត្រីត្រួតពិនិត្យ និងលក្ខខណ្ឌតម្រូវនានាដែលពាក់ព័ន្ធនឹងបច្ចេកទេស។

រដ្ឋបាលរាជធានី/ខេត្ត.......................... សង្ឃឹម និងជឿជាក់ថាលោក លោកស្រីនឹងយកចិត្តទុកដាក់ និងសហការអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឲ្យមានប្រសិទ្ធភាពប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ.......................... ខែ...........ឆ្នាំ......... ព.ស.២៥៦...
រាជធានី/ខេត្ត........... ថ្ងៃទី......ខែ............ឆ្នាំ២០......
**អភិបាលនៃគណៈអភិបាលរាជធានី/ខេត្ត.........**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
  "ដើម្បីគោរពជូនជ្រាបជាព័ត៌មាន"
- មន្ទីរក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី/ខេត្ត........
  "ដើម្បីអនុវត្ត"
- គ្រប់សាលាក្រុង/ខណ្ឌ/ស្រុក
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Logo រដ្ឋបាល
រាជធានី/ខេត្ត

**រដ្ឋបាលរាជធានី/ខេត្ត.............**

លេខ.........................................

# កម្មវិធី

## ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ (ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេង នៅតាមស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈដែលត្រូវបានដាក់ពាក្យស្នើសុំ នៅអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាល រាជធានី/ខេត្ត......

**យោង** ៖ - សេចក្ដីជូនដំណឹងស្ដីពីការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេង សម្រាប់ឆ្នាំ..............របស់រដ្ឋបាលរាជធានី/ខេត្ត..................................

- ពាក្យស្នើសុំរបស់បណ្ដាស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈដែលបញ្ជូនមកការិយាល័យជួរក្រោយ
- យោងតាមទីតាំងស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈដែលមាននៅតាមភូមិសាស្ត្រក្រុង/ស្រុក/ខណ្ឌ
- កាលបរិច្ឆេទនៃការបញ្ជូនពាក្យស្នើសុំពីការិយាល័យជួរក្រោយ

| ល.រ | ឈ្មោះ ក្រុង/ស្រុក/ខណ្ឌ | ឈ្មោះ ស្ថានីយ/អនុស្ថានីយ (ដេប៉ូ) | ចំនួន | | កាលបរិច្ឆេទ ទទួលពាក្យ ពីជួរក្រោយ | កាលបរិច្ឆេទ ចុះត្រួតពិនិត្យ ផ្ទៀងផ្ទាត់ | កាលបរិច្ឆេទបញ្ជូន ឯកសារត្រួតពិនិត្យ ផ្ទៀងផ្ទាត់ត្រឡប់ ទៅជួរក្រោយវិញ |
|---|---|---|---|---|---|---|---|
| | | | ដៃ បាញ់ប្រេង | ដៃរវៃបូម ប្រេង | | | |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| សរុប | | | | | | | |

ថ្ងៃ.......................ខែ...............ឆ្នាំ.................ព.ស.២៥....
................ថ្ងៃទី........... ខែ ................ឆ្នាំ ២០.....
អ្នកធ្វើកម្មវិធីត្រួតពិនិត្យ

ថ្ងៃ......................ខែ............ឆ្នាំ............ព.ស.២៥....
................ថ្ងៃទី........... ខែ ................ឆ្នាំ ២០......
ប្រធានអង្គភាពច្រកចេញចូលតែមួយ រាជធានី/ខេត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Logo រដ្ឋបាល
រាជធានី/ខេត្ត

**រដ្ឋបាលរាជធានី/ខេត្ត.............**
លេខ.........................................

# កម្មវិធី
## ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ (ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេង នៅតាមស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈ នៃរដ្ឋបាល រាជធានី/ខេត្ត......

**យោង** ៖ - សេចក្តីជូនដំណឹងស្តីពីការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ឬដៃរវៃបូមប្រេង សម្រាប់ឆ្នាំ..............របស់រដ្ឋបាលរាជធានី/ខេត្ត..................................
- យោងតាមទីតាំងស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ប្រេងឥន្ធនៈដែលមាននៅតាមភូមិសាស្ត្រក្រុង/ស្រុក/ខណ្ឌ

| ល.រ | ឈ្មោះក្រុង/ស្រុក/ខណ្ឌ | ឈ្មោះស្ថានីយ/អនុស្ថានីយ(ដេប៉ូ) | ចំនួន | | កាលបរិច្ឆេទ ចុះត្រួតពិនិត្យផ្ទៀងផ្ទាត់ |
|---|---|---|---|---|---|
| | | | ដៃ បាញ់ប្រេង | ដៃរវៃ បូមប្រេង | |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| សរុប | | | | | |

ថ្ងៃ.........................ខែ................ឆ្នាំ..................ព.ស.២៥....
................ថ្ងៃទី........... ខែ ................ឆ្នាំ ២០......
អ្នកធ្វើកម្មវិធីត្រួតពិនិត្យ

ថ្ងៃ.....................ខែ............ឆ្នាំ............ព.ស.២៥....
................ថ្ងៃទី........... ខែ ................ឆ្នាំ ២០......
ប្រធានអង្គភាពច្រកចេញចូលតែមួយ រាជធានី/ខេត្ត

Logo រដ្ឋបាល
រាជធានី/ខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី/ខេត្ត**.............
លេខ..........................................

# លិខិតជួសជុលកែតម្រូវ

- ស្ថាប័នត្រួតពិនិត្យ ៖ មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី/ខេត្ត......................
- ឈ្មោះម្ចាស់ឧបករណ៍ ៖ ..........................................................................................................
- អាសយដ្ឋានម្ចាស់ឧបករណ៍ ៖ ..........................................................................................................
- ទីតាំងប្រើប្រាស់ឧបករណ៍ ៖ ..........................................................................................................
- ប្រភេទឧបករណ៍ ៖ ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃវ៉ែប្អូមប្រេង

| ល.រ | ម៉ូឌែលដៃវ៉ែប្អូមប្រេង | លេខកូដ | ចន្លោះក្រិតអប្បរមា និងអតិបរមា | ប្រទេសផលិត | លទ្ធផល |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |

ទិន្នន័យខាងលើ យោងតាមកំណត់ហេតុបច្ចេកទេសនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ (ប្រេងឥន្ធនៈ) ជាដៃវ៉ែប្អូមប្រេង ដោយមន្ត្រីត្រួតពិនិត្យឈ្មោះ........................................................................ តួនាទី......................................ចុះថ្ងៃទី............ខែ.........ឆ្នាំ២០...... ។

## សម្រេច

មិនអនុញ្ញាតឱ្យប្រើប្រាស់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃវ៉ែប្អូមប្រេង ដូចមានក្នុងតារាងខាងលើនេះ នៅក្នុងសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្ម ចាប់ពីថ្ងៃទី.............ខែ...........ឆ្នាំ២០.... តទៅ និងត្រូវជួសជុលកែតម្រូវឲ្យបានរួចរាល់ ហើយត្រូវដាក់ពាក្យស្នើសុំត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង មុននឹងប្រើប្រាស់ឡើងវិញ។

<u>**បញ្ជាក់៖**</u> ក្រុមហ៊ុន/អង្គភាព/ជាង ជួសជុល ត្រូវមានអាជ្ញាប័ណ្ណផលិត និងជួសជុលឧបករណ៍មាត្រាសាស្ត្រ ដែលទទួលស្គាល់ដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។

ថ្ងៃ.......................ខែ...............ឆ្នាំ....................ព.ស.២៥.....
................ថ្ងៃទី........... ខែ ...............ឆ្នាំ ២០.....
**អភិបាល**..........

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ)

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................អក្សរឡាតាំង.................................ឆ្នាំកំណើត..................
តួនាទី.......................................ក្រុមហ៊ុន/ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)...................................................
អាសយដ្ឋានក្រុមហ៊ុន/ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)ផ្ទះលេខ.............ផ្លូវ........................ឃុំ/សង្កាត់...................
ក្រុង/ស្រុក/ខណ្ឌ.......................................................រាជធានី/ខេត្ត.....................................................
ទូរសព្ទលេខ.......................................................អ៊ីម៉ែល...............................................................

**សូមគោរពជូន**

**ឯកឧត្តម-លោកជំទាវអភិបាលនៃគណៈអភិបាល រាជធានី/ខេត្ត**.........

**<u>កម្មវត្ថុ</u>** ៖ សំណើសុំត្រួតពិនិត្យផ្ទៀងផ្ទាត់៖

១. ដៃបាញ់ប្រេង ☐ លើកដំបូង ☐ ក្នុងពេលប្រើប្រាស់

២. ដៃរង្វើបូមប្រេង ☐ លើកដំបូង ☐ ក្នុងពេលប្រើប្រាស់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តម-លោកជំទាវអភិបាល** មេត្តាជ្រាបថា៖ ខ្ញុំបាទ/នាងខ្ញុំមានបំណងប្រើប្រាស់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ដើម្បីធ្វើអាជីវកម្ម ពាណិជ្ជកម្ម ឬសេវាកម្មដូចបញ្ជាក់ក្នុងតារាងភ្ជាប់ជូននៅខាងក្រោម។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម-លោកជំទាវអភិបាល** មេត្តាពិនិត្យ និងអនុញ្ញាតដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម-លោកជំទាវអភិបាល** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

.......................ថ្ងៃទី...........ខែ.............ឆ្នាំ............

**ម្ចាស់ស្ថានីយ**/អនុស្ថានីយ(ដេប៉ូ)

***<u>សំណុំឯកសារភ្ជាប់៖</u>***

១. បញ្ជីឈ្មោះឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ចំនួន ១ ច្បាប់

២. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លង(សម្រាប់ប្រជាពលរដ្ឋខ្មែរ)
ឬលិខិតឆ្លងដែនថតចម្លង(សម្រាប់ជនបរទេស)ដែលមានការបញ្ជាក់ពីអាជ្ញាធរ
ឬស្ថាប័នមានសមត្ថកិច្ច ឬមានការផ្តិតមេដៃទទួលស្គាល់ដោយសាមីខ្លួន ចំនួន ១ ច្បាប់

៣. លិខិតអនុញ្ញាតប្រើប្រាស់លើកដំបូង ឬក្នុងពេលប្រើប្រាស់លើកមុន ថតចម្លង(ករណីស្នើសុំបន្ត) ចំនួន ១ ច្បាប់

# បញ្ជីឈ្មោះឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ដែលស្នើសុំធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់

| ល.រ | ម៉ូឌែល ម៉ាស៊ីន | លេខកូដ ម៉ាស៊ីន | លេខកូដ ដៃបាញ់ប្រេង | លំហូរអប្បរមា និងអតិបរមា | ប្រទេសផលិត | ទីកន្លែង កំពុងប្រើប្រាស់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ០១ | | | | | | | |
| ០២ | | | | | | | |
| ០៣ | | | | | | | |
| ០៤ | | | | | | | |
| ០៥ | | | | | | | |
| ០៦ | | | | | | | |
| ០៧ | | | | | | | |
| ០៨ | | | | | | | |
| ០៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |
| ១៣ | | | | | | | |
| ១៤ | | | | | | | |
| ១៥ | | | | | | | |
| ១៦ | | | | | | | |
| ១៧ | | | | | | | |
| ១៨ | | | | | | | |
| ១៩ | | | | | | | |
| ២០ | | | | | | | |
| ២១ | | | | | | | |
| ២២ | | | | | | | |
| ២៣ | | | | | | | |
| ២៤ | | | | | | | |
| ២៥ | | | | | | | |

ធ្វើនៅ..................... ថ្ងៃទី...........ខែ.............ឆ្នាំ...............

ហត្ថលេខា ឬស្នាមមេដៃម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)

# បញ្ជីឈ្មោះឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃរវៃបូមប្រេង
# ដែលស្នើសុំធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់

| ល.រ | ម៉ូឌែល ដៃរវៃបូមប្រេង | លេខកូដ | ចន្លោះក្រិត អប្បរមា និងអតិបរមា | ប្រទេសផលិត | ទីកន្លែង កំពុងប្រើប្រាស់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ០១ | | | | | | |
| ០២ | | | | | | |
| ០៣ | | | | | | |
| ០៤ | | | | | | |
| ០៥ | | | | | | |
| ០៦ | | | | | | |
| ០៧ | | | | | | |
| ០៨ | | | | | | |
| ០៩ | | | | | | |
| ១០ | | | | | | |
| ១១ | | | | | | |
| ១២ | | | | | | |
| ១៣ | | | | | | |
| ១៤ | | | | | | |
| ១៥ | | | | | | |
| ១៦ | | | | | | |
| ១៧ | | | | | | |
| ១៨ | | | | | | |
| ១៩ | | | | | | |
| ២០ | | | | | | |
| ២១ | | | | | | |
| ២២ | | | | | | |
| ២៣ | | | | | | |
| ២៤ | | | | | | |
| ២៥ | | | | | | |

ធ្វើនៅ...................... ថ្ងៃទី............ខែ..............ឆ្នាំ................

ហត្ថលេខា ឬស្នាមមេដៃម្ចាស់ស្ថានីយ/អនុស្ថានីយ(ដេប៉ូ)

Logo រដ្ឋបាល
រាជធានី/ខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី/ខេត្ត**.............
លេខ.........................................

# លិខិតជួសជុលកែតម្រូវ

- ស្ថាប័នត្រួតពិនិត្យ ៖ មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី/ខេត្ត.......................
- ឈ្មោះម្ចាស់ឧបករណ៍ ៖ ..........................................................................................
- អាសយដ្ឋានម្ចាស់ឧបករណ៍ ៖ ..........................................................................................
- ទីតាំងប្រើប្រាស់ឧបករណ៍ ៖ ..........................................................................................
- ប្រភេទឧបករណ៍ ៖ ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង

| ល.រ | ម៉ូឌែលម៉ាស៊ីន | លេខកូដម៉ាស៊ីន | លេខកូដ ដៃបាញ់ប្រេង | លំហូរអប្បរមា និងអតិបរមា | ប្រទេសផលិត | លទ្ធផល |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |

ទិន្នន័យខាងលើ យោងតាមកំណត់ហេតុបច្ចេកទេសនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ (ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ដោយមន្ត្រីត្រួតពិនិត្យឈ្មោះ.................................................................... តួនាទី...................................ចុះថ្ងៃទី............ខែ.........ឆ្នាំ២០...... ។

## សម្រេច

មិនអនុញ្ញាតឱ្យប្រើប្រាស់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ដូចមានក្នុងតារាងខាងលើនេះ នៅក្នុងសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្ម ចាប់ពីថ្ងៃទី.............ខែ...........ឆ្នាំ២០.... តទៅ និងត្រូវជួសជុលកែតម្រូវឲ្យបានរួចរាល់ ហើយត្រូវដាក់ពាក្យស្នើសុំត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង មុននឹងប្រើប្រាស់ឡើងវិញ។

**<u>បញ្ជាក់៖</u>** ក្រុមហ៊ុន/អង្គភាព/ជាង ជួសជុល ត្រូវមានអាជ្ញាប័ណ្ណផលិត និងជួសជុលឧបករណ៍មាត្រាសាស្ត្រ ដែលទទួលស្គាល់ដោយមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។

ថ្ងៃ.......................ខែ...............ឆ្នាំ....................ព.ស.២៥.....
................ថ្ងៃទី........... ខែ ...............ឆ្នាំ ២០.....
**អភិបាល**..........

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Logo រដ្ឋបាល
រាជធានី/ខេត្ត

**រដ្ឋបាលរាជធានី/ខេត្ត....................**

លេខ .............................

# លិខិតអនុញ្ញាតប្រើប្រាស់

- ស្ថាប័នត្រួតពិនិត្យ ៖ មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី/ខេត្ត.......................................................
- ឈ្មោះម្ចាស់ឧបករណ៍ ៖ ..........................................................................................................
- អាសយដ្ឋានម្ចាស់ឧបករណ៍ ៖ ..........................................................................................................
- ទីតាំងប្រើប្រាស់ឧបករណ៍ ៖ ..........................................................................................................
- ប្រភេទឧបករណ៍ ៖ ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃវ៉ែបូមប្រេង

| ល.រ | ម៉ូឌែលដៃវ៉ែបូមប្រេង | លេខកូដ | ចន្លោះក្រិត អប្បរមា និងអតិបរមា | ប្រទេសផលិត | លេខកូដសៀល | លេខកូដ សញ្ញាត្រួតពិនិត្យ | លទ្ធផល |
|---|---|---|---|---|---|---|---|
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |

ទិន្នន័យខាងលើ យោងតាមកំណត់ហេតុបច្ចេកទេសនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃវ៉ែបូមប្រេង ដោយមន្ត្រីត្រួតពិនិត្យ ឈ្មោះ ........................ តួនាទី............................................ចុះថ្ងៃទី............ខែ.........ឆ្នាំ២០...... ។

**សម្រេច**

អនុញ្ញាតឱ្យប្រើប្រាស់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃវ៉ែបូមប្រេង ដូចមានក្នុងតារាងខាងលើនេះ នៅក្នុងសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្ម និងត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់លើកក្រោយ នៅត្រឹមថ្ងៃទី...........ខែ...........ឆ្នាំ២០........។

ថ្ងៃ.......................ខែ...............ឆ្នាំ...................ព.ស.២៥....

................ថ្ងៃទី........... ខែ ...............ឆ្នាំ ២០......

**អភិបាល..........**

ONE WINDOW SERVICE UNIT

Logo រដ្ឋបាលរាជធានី/ខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី/ខេត្ត....................**

លេខ .............................

# លិខិតអនុញ្ញាតប្រើប្រាស់

- ស្ថាប័នត្រួតពិនិត្យ ៖ មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានី/ខេត្ត............................................................
- ឈ្មោះម្ចាស់ឧបករណ៍ ៖ ........................................................................................................................
- អាសយដ្ឋានម្ចាស់ឧបករណ៍ ៖ ........................................................................................................................
- ទីតាំងប្រើប្រាស់ឧបករណ៍ ៖ ........................................................................................................................
- ប្រភេទឧបករណ៍ ៖ ឧបករណ៍បែងចែកវត្ថុរាវ( ប្រេងឥន្ធនៈ ) ជាដៃបាញ់ប្រេង

| ល.រ | ម៉ូឌែលម៉ាស៊ីន | លេខកូដម៉ាស៊ីន | លេខកូដ ដៃបាញ់ប្រេង | លំហូរអប្បរមា និងអតិបរមា | ប្រទេសផលិត | លេខកូដសៀល | លេខកូដ សញ្ញាត្រួតពិនិត្យ | លទ្ធផល |
|---|---|---|---|---|---|---|---|---|
| ១ | | | | | | | | |
| ២ | | | | | | | | |
| ៣ | | | | | | | | |
| ៤ | | | | | | | | |
| ៥ | | | | | | | | |
| ៦ | | | | | | | | |

ទិន្នន័យខាងលើ យោងតាមកំណត់ហេតុបច្ចេកទេសនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ដោយមន្ត្រីត្រួតពិនិត្យ ឈ្មោះ ......................... តួនាទី.............................................ចុះថ្ងៃទី............ខែ.........ឆ្នាំ២០...... ។

**សម្រេច**

អនុញ្ញាតឱ្យប្រើប្រាស់ឧបករណ៍បែងចែកវត្ថុរាវ(ប្រេងឥន្ធនៈ) ជាដៃបាញ់ប្រេង ដូចមានក្នុងតារាងខាងលើនេះ នៅក្នុងសកម្មភាពពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្ម និងត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់លើកក្រោយ នៅត្រឹមថ្ងៃទី..........ខែ...........ឆ្នាំ២០........។

ថ្ងៃ.......................ខែ...............ឆ្នាំ.....................ព.ស.២៥....

................ថ្ងៃទី........... ខែ ...............ឆ្នាំ ២០......

**អភិបាល..........**